ខេត្តព្រៃវែង

សក្តានុពលវិនិយោគ

សីហា ឆ្នាំ ២០០៨




# ខេត្តព្រៃវែង
## តំបន់អាជីវកម្មដែលមិនទាន់បានប្រើប្រាស់របស់កម្ពុជា






USAID
ជំនួយពីពលរដ្ឋអាមេរិក

**បញ្ជាក់:**
ទស្សនៈរបស់អ្នកនិពន្ធដែលបង្ហាញនៅក្នុងឯកសារបោះពុម្ពផ្សាយនេះ មិនបានឆ្លុះបញ្ចាំងអំពីទស្សនៈរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិក ដើម្បីអភិវឌ្ឍន៍អន្តរជាតិ ឬ រដ្ឋាភិបាលអាមេរិកនោះទេ។



# របាយការណ៍វិនិយោគខេត្តព្រៃវែង


**មតិស្វាគមន៍ពីឯកឧត្តមអភិបាលខេត្ត** ២

**ចំណុចខ្លាំងរបស់ប្រទេស** ៣

បរិយាកាសអាជីវកម្មបើកចំហ
កំលាំងពលកម្មដែលមានតម្លៃឈ្នួលពលកម្មទាប
ទីតាំងយុទ្ធសាស្ត្រក្នុងតំបន់

**តើហេតុអ្វីជ្រើសរើសយកខេត្តព្រៃវែង?** ៤

១. ទីតាំង និងបណ្តាញផ្លូវគោកល្អប្រសើរ
២. កំលាំងពលកម្ម - ច្រើន វ័យក្មេង តម្លៃទាប
៣. វិស័យសេវាហិរញ្ញវត្ថុដ៏ក្លាំងក្លា
៤. អចលនទ្រព្យដែលមានតម្លៃខ្ពស់លើសលប់ លក់ក្នុងតម្លៃទាប
៥. សេវាទឹក និងអគ្គិសនីដែលមានលក្ខណៈប្រកួតប្រជែង

**ឧស្សាហកម្មសំខាន់ៗរបស់ខេត្ត** ៥

កសិកម្ម
ឧស្សាហកម្ម

**ឱកាសអាជីវកម្ម** ៦

**ការអភិវឌ្ឍន៍ដែលកំពុងដំណើរការ** ៦

**ត្រូវការស្វែងយល់បន្ថែមទៀតទេ?** ៧



របាយការណ៍វិនិយោគនេះផលិតដោយ EMC សំរាប់គំរោងអភិវឌ្ឍន៍សហគ្រាសខ្នាតតូចបំផុត ខ្នាតតូច និងខ្នាតមធ្យម
នៅកម្ពុជា ដែលអនុវត្តគំរោងដោយអង្គការ DAI ឧបត្ថម្ភថវិកាដោយ ទីភ្នាក់ងារសហរដ្ឋអាមេរិក ដើម្បីអភិវឌ្ឍន៍អន្តរជាតិ ។








## មតិស្វាគមន៍ពីឯកឧត្តមអភិបាលខេត្ត

ព្រៃវែងគឺជាខេត្តដែលមានទីតាំងល្អ ស្ថិតនៅចន្លោះទីក្រុងភ្នំពេញ និងទីក្រុងហូជីមិញ។ ផ្លូវជាតិលេខមួយគឺជាផ្លូវជាតិ ដែលមានភាពមមាញឹកបំផុតរបស់កម្ពុជាដោយឆ្លងកាត់ខេត្តនេះទាំងមូល ហើយជាបណ្តាញផ្លូវដ៏ល្អមួយដែលតភ្ជាប់ទៅទីផ្សារសេដ្ឋកិច្ចសំខាន់ក្នុងតំបន់សំរាប់អាជីវកម្មរបស់យើង ។

ខេត្តមានទីតាំងនៅត្រើយខាងកើតនៃដងទន្លេមេគង្គ ដែលផ្តល់ប្រភពទឹកសំរាប់វិស័យកសិកម្ម និងគមនាគមន៍ ។

ខេត្តព្រៃវែងគឺជាជម្រុកស្រូវដ៏ធំមួយនៅក្នុងប្រទេសកម្ពុជា។ យើងក៏មានត្រី មាន់ ទា និងជ្រូកជាច្រើន រួមទាំងដំណាំផ្សេងៗទៀតផងដែរ។ ទោះជាយ៉ាងណាក៏ដោយខេត្តរបស់យើងពុំមែនជាខេត្តដែលពឹងផ្អែកលើវិស័យកសិកម្មតែមួយមុខនោះទេ ។ ទីតាំងខេត្តយើងបានតំរង់ទិសឱ្យវិនិយោគិនទាំងឡាយ ក្នុងការស្នើសុំឱ្យខេត្តព្រៃវែងនេះក្លាយជាទីតាំងសំរាប់រោងចក្រកាត់ដេរសំលៀកបំពាក់ថ្មីមួយ ។

ខេត្តរបស់យើងមានទំហំមធ្យម ។ ប៉ុន្តែមានចំនួនប្រជាជនយ៉ាងច្រើន មនុស្សពេញវ័យពេញកំលាំងធ្វើការ ហើយឧស្សាហ៍ព្យាយាមក្នុងការងារចំនួនមួយលាននាក់ ។

ដើម្បីបន្តលើកកំពស់មូលដ្ឋានសេដ្ឋកិច្ចរបស់ប្រទេសយើង អាជ្ញាធរខេត្តព្រៃវែងបានបំពេញការងាររបស់ខ្លួនយ៉ាងសកម្ម ដើម្បីពង្រឹងបរិយាកាសអាជីវកម្ម។

ទោះជាយ៉ាងណាក៏ដោយ ក៏យើងមិនបញ្ឈប់ត្រឹមនេះដែរ យើងនៅតែបន្តកែលំអខេត្តរបស់យើង ឱ្យកាន់តែមានការទាក់ទាញខាងវិនិយោគទុនបន្ថែមទៀត ព្រមទាំងថែរក្សាសហគ្រាសអាជីវកម្ម ដែលមានស្រាប់ឱ្យបានគង់វង្សទៀតផង ។ យើងរីករាយចំពោះសក្តានុពលក្នុងការពង្រឹង និងពង្រីកមូលដ្ឋានឧស្សាហកម្មរបស់យើង ព្រមទាំងបើកចំហទទួលស្វាគមន៍វិនិយោគិនទាំងក្នុង និងក្រៅប្រទេសថែមទៀត។ យើងនឹងព្យាយាមឱ្យអស់ពីលទ្ធភាព ដើម្បីបង្កលក្ខណៈងាយស្រួល និងធ្វើឱ្យវិនិយោគិនចំណាយធនធានតិចក្នុងការបង្កើត និងការប្រកបមុខជំនួញរបស់ពួកគេ ហើយយើងនឹងប្រឹងប្រែងបំពេញភារកិច្ចរបស់យើង ក្នុងការផ្តល់បរិយាកាសអាជីវកម្មប្រកបដោយសេរីភាពនិងអាចទុកចិត្តបាន ។

ខ្ញុំសូមថ្លែងអំណរគុណដល់ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ ដែលបានជួយឧបត្ថម្ភក្នុងការរៀបចំបង្កើតរបាយការណ៍វិនិយោគ និងបានបន្តគាំទ្រលើការផ្សព្វផ្សាយការអភិវឌ្ឍន៍វិស័យឯកជននៅក្នុងខេត្តរបស់យើងខ្ញុំ។

ខ្ញុំទន្ទឹងរង់ចាំធ្វើការជាមួយវិនិយោគិនទាំងអស់ ដើម្បីជួយធ្វើឱ្យពាណិជ្ជកម្មរបស់ពួកគេព្រមទាំងខេត្តដែលមានសក្តានុពលរបស់យើងនេះ កាន់តែមានភាពរីកចំរើនឡើងថែមទៀត។

សូមទទួលនូវការគោរពដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

**ឯកឧត្តម អ៊ុង សាមី**
អភិបាលខេត្តព្រៃវែង





## ចំណុចខ្លាំងរបស់ប្រទេស

ជាងមួយទសវត្សរ៍ចុងក្រោយនេះ ប្រទេសកម្ពុជាបានចេញមុខជាអ្នកប្រកួតប្រជែងក្នុងតំបន់ដ៏រឹងមាំ និងសកម្មដោយមានភោគទ្រព្យយ៉ាងសម្បូរបែប ដែលមានសារៈសំខាន់បំផុតសំរាប់កំណើន និងការអភិវឌ្ឍន៍អាជីវកម្មប្រកបដោយជោគជ័យ ។

### បើកទូលាយសំរាប់អាជីវកម្ម

- ពន្ធលើប្រាក់ចំណេញដែលមានតម្លៃទាប-ពន្ធ ២០% លើប្រាក់ ចំណេញ ( ការខាតបង់ ៥ ឆ្នាំទៅមុខ)
- ពុំមានការកំណត់លក្ខខណ្ឌកាន់កាប់បរទេសទេ ។ ប្រទេសកម្ពុជា អនុញ្ញាតឱ្យសម្ព័ន្ធអាជីវកម្មរួមគ្នា ឬក្រុមហ៊ុនដែលកាន់កាប់ដោយបរទេសប្រត្តិបត្តិការ១០០% ដោយមានសិទ្ធិពេញលេញដែលអាចនាំចូល និងនាំចេញផលិតផលបានស្ទើរគ្រប់ប្រភេទ ។
- វិនិយោគិនទាំងអស់ទទួលបានការការពារប្រកបដោយសមភាព ។
- ប្រទេសកម្ពុជាមានសេរីភាពខាងសេដ្ឋកិច្ចជាងប្រទេសចិន ឥណ្ឌា វៀតណាម និងឥណ្ឌូនេស៊ី[1] ។
- ពុំមានការគ្រប់គ្រងតម្លៃផលិតផល ឬសេវាណាមួយទេ ។
- ពុំមានការគ្រប់គ្រងការប្តូររូបិយប័ណ្ណបរទេស ឬការកំណត់លក្ខខណ្ឌទៅលើការប្តូររូបិយប័ណ្ណនេះទេ ។
- ពុំមានការកំណត់លក្ខខណ្ឌស្តីពីការបង្វិលទុនទេ ។
- សមាជិកភាពអង្គការពាណិជ្ជកម្មពិភពលោក និងអាស៊ាន ។
- ពុំមានការកំណត់លក្ខខណ្ឌពាណិជ្ជកម្មបរិមាណ និងពុំមានការទំលាក់ថ្លៃរបាំងពន្ធគយទេ ។ ប្រទេសកម្ពុជាអាចទទួលបានការលើកលែងពន្ធ និងការកំណត់កូតានៅលើទីផ្សារពិភពលោកធំៗ (ដូចជាសហរដ្ឋអាមេរិក សហភាពអឺរ៉ុប ជប៉ុន និងបណ្តាប្រទេសសមាជិកអាស៊ានជាច្រើនទៀត ) ។
- អជ្ញាធរខេត្តមានសិទ្ធិអនុម័តការវិនិយោគទុនក្រោម ២លានដុល្លារ ដើម្បីការចាប់ផ្តើមអភិវឌ្ឍន៍អាជីវកម្មឆាប់រហ័ស ។

*"ប្រទេសកម្ពុជា បើកទូលាយយ៉ាងពេញលេញសំរាប់អជីវកម្ម ហើយរាជរដ្ឋាភិបាលកម្ពុជានឹងព្យាយាមឱ្យអស់ពីសមត្ថភាព ដើម្បីធានានូវបរិយាកាសគួរជាទីពេញចិត្ត និងជោគជ័យដល់គ្រប់សហគ្រាសទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។"*

*- សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្រ្តីនៃព្រះរាជាណាចក្រកម្ពុជា*

### កំលាំងពលកម្មដែលមានតម្លៃទាប

បើប្រៀបធៀបទៅនឹងដៃគូប្រកួតប្រជែងជាច្រើនក្នុងតំបន់ ប្រទេសកម្ពុជារីករាយនឹងទទួលយកអត្រាប្រាក់ឈ្នួលទាបសមរម្យ ក្នុងគោលបំណងទាក់ទាញឧស្សាហកម្មដែលប្រើកំលាំងពលកម្មច្រើន ។

ឆ្លងកាត់ជាច្រើនឆ្នាំចុងក្រោយនេះ កំលាំងពលកម្មនៅប្រទេសកម្ពុជា បានកើនឡើងជាង ៥០% ច្រើនជាងពីរដងនៃអត្រានៅក្នុងប្រទេសសមាជិកអាស៊ានផ្សេងទៀត[2] ។ ហើយដោយសារមានប្រជាជនវ័យក្មេងចំនួនច្រើន (ចំនួនពាក់កណ្តាលមានអាយុក្រោម ២០ឆ្នាំ ) ទើបធ្វើឱ្យកំណើននៃកំលាំងពលកម្មនេះ នឹងបន្តកើនឡើង ។

### ប្រាក់ឈ្នួលក្នុងឧស្សាហកម្មកាត់ដេរ[3]

| ប្រទេស | អត្រាប្រាក់ឈ្នួលក្នុងមួយម៉ោង (US$) |
|---|---|
| កម្ពុជា | 0.33 |
| ចិន | 0.88[a]/0.66[b] |
| ប៉ាគីស្ថាន | 0.41 |
| ឥណ្ឌា | 0.38 |
| ឥណ្ឌូនេស៊ី | 0.30 |
| បង់ក្លាដេស | 0.39 |

### ទីតាំងយុទ្ធសាស្រ្តក្នុងតំបន់

ប្រទេសកម្ពុជាមានទីតាំងស្ថិតនៅចំកណ្តាលតំបន់ ដែលមានសក្តានុពលបំផុតនៅលើពិភពលោក ។ ស្ថិតនៅកណ្តាលប្រទេសថៃ និងប្រទេសវៀតណាម ប្រទេសកម្ពុជាគឺជាផ្នែកមួយនៃច្រកសេដ្ឋកិច្ចខាងត្បូងនៃមហាអនុតំបន់ទន្លេមេគង្គ ដែលលាតសន្ធឹងចេញពីទីក្រុងហូជីមិញរហូត ដល់ទីក្រុងបាងកក ។

ដោយសារទីតាំងយុទ្ធសាស្រ្តរបស់ខ្លួន ប្រទេសកម្ពុជាបានរីករាយនឹងទទួលយកការគាំទ្រពីសំណាក់អន្តរជាតិដ៏សំខាន់ៗ ក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនរបស់ខ្លួនដើម្បីសម្រួលដល់ពាណិជ្ជកម្មក្នុងប្រទេស និងជាមួយប្រទេសជិតខាង ។ ជាលទ្ធផល ពាណិជ្ជកម្មជាមួយនឹងប្រទេសវៀតណាម និងប្រទេសថៃកំពុងតែរីកចម្រើនឡើងយ៉ាងឆាប់រហ័ស ។




*"អ្នកមានទីក្រុងធំជាងគេចំនួនពីរនៅក្នុងអាស៊ីដែលនៅអមប្រទេសអ្នក ។ អ្នកមានប្រជាជន១៥លាននាក់នៅទីក្រុងបាងកក និង៨លាននាក់នៅទីក្រុងហូជីមិញ ហើយកំណើនផ្សេងៗមានការកើនឡើងជាលំដាប់ នៅភាគកណ្តាលនៃទីក្រុងទាំងពីរ ។"*

- Edward Hopkins, CB Richard Ellis Group Inc.

1. *The Heritage Foundation លិបិក្រមនៃសេរីភាពសេដ្ឋកិច្ច ឆ្នាំ២០០៨ ។* http://www.heritage.org/index/
2. *និន្នាការសង្គម និងពលកម្មនៅអាស៊ាន ឆ្នាំ ២០០៧ -សមាហរណកម្មការប្រឈមមុខ និងកាលានុវត្តភាព ឆ្នាំ ២០០៧ ។*

3. *ចំណាំ: a) តំបន់ឆ្នេរ b) តំបន់ដីគោក*
*ប្រភព: បាហ្គាវី (Bargawi) "ឧស្សាហកម្មកាត់ដេរកម្ពុជា -ប្រភព និងការរំពឹងទុកពេលអនាគត" វិទ្យាស្ថានអភិវឌ្ឍការគ្រប់គ្រង ឆ្នាំ ២០០៥ ។*





# តើហេតុអ្វីជ្រើសរើសយកខេត្តព្រៃវែង?

## ១. ទីតាំង និងបណ្ដាញផ្លូវគោកល្អប្រសើរ

ខេត្តព្រៃវែងមានទីតាំងស្ថិតនៅក្នុងច្រកដឹកជញ្ជូន និងពាណិជ្ជកម្មសំខាន់នៅចន្លោះទីក្រុងភ្នំពេញ រាជធានីកម្ពុជា និងទីក្រុងហូជីមិញ ប្រទេសវៀតណាម។ ដោយមានផ្លូវជាតិប្រកបដោយគុណភាពខ្ពស់តភ្ជាប់ទីក្រុងទាំងពីរនេះ ខេត្តព្រៃវែងមានផ្លូវដ៏ល្អតភ្ជាប់ទៅនឹងទីផ្សារនាំចេញ និងក្នុងស្រុក ។

ខេត្តនេះមានហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនល្អប្រសើរ។ ខេត្តព្រៃវែងមានផ្លូវជាតិដែលប្រកបដោយគុណភាពខ្ពស់ចំនួន ៦ ឆ្លងកាត់ ។ ជាលទ្ធផល ខេត្តនេះមានផ្លូវជាតិជាច្រើនគីឡូម៉ែត្រ (១៥៩គម) ដែលមានទំហំធំជាងផ្លូវជាតិទូទាំងប្រទេសគិតជាមធ្យម ។

ទីរួមខេត្តព្រៃវែងឆ្លងកាត់ដោយផ្លូវជាតិលេខ១១ "ល្អដូចផ្លូវផ្សេងៗទៀតនៅក្នុងប្រទេសដែរ"[4] ដែលផ្លូវនេះតភ្ជាប់ខេត្តកំពង់ចាម និងអ្នកលឿង។ ពីភ្នំពេញមកទីរួមខេត្តព្រៃវែងបើកបរអស់រយៈពេលតែ២ម៉ោងកន្លះទេ ហើយពីទីក្រុងហូជីមិញមកទីរួមខេត្តព្រៃវែងបើកបរអស់រយៈពេល៣ម៉ោង ។

**កម្ពុជា_ខេត្តព្រៃវែង រយៈពេលធ្វើដំណើរតាមរថយន្តទៅកាន់ទីរួមខេត្តឬក្រុងនានា**




សញ្ញាព្រួញតំណាងឱ្យរយៈពេលនៃការធ្វើដំណើរដោយរថយន្តគិតជាម៉ោងរយៈពេលធ្វើដំណើរទៅកាន់ទីក្រុង បាងកក និង ហូជីមិញ មិនរាប់បញ្ចូលរយៈពេលឆ្លងកាត់ព្រំដែនទេ។

ផ្លូវជាតិថ្មីលេខ ៨ (កំពុងកសាង) តភ្ជាប់ទៅព្រំប្រទល់វៀតណាម ត្រូវបានរំពឹងថាផ្ដល់ឱកាសដល់អាជីវកម្ម និងមុខជំនួញដែលមានការកើនឡើង ។

## ២. កំលាំងពលកម្ម-ច្រើន វ័យក្មេង តម្លៃទាប

ចំនួនប្រជាជនរបស់យើងមានជាង ១ លាននាក់ បានធ្វើឱ្យខេត្តរបស់យើងជាខេត្តមួយដែលមានចំនួនប្រជាជនច្រើនក្នុងចំណោមខេត្តដែលមានប្រជាជនច្រើនជាងគេនៅក្នុងប្រទេស។ចំនួនប្រជាជននេះស្ទើរតែជាងពាក់កណ្ដាលមានអាយុក្រោម ២៥ឆ្នាំ ទើបកំលាំងពលកម្មរបស់យើងមានវ័យក្មេងពេញចិត្ត នឹងការងារ និងមានការអប់រំ ។

ការចំណាយទៅលើការអប់រំនៅបឋមសិក្សា ដែលជាផ្នែកមួយនៃផលិតផលក្នុងស្រុកសរុប(GDP) បានកើនឡើងគួរឱ្យកត់សំគាល់នៅក្នុងប្រទេសកម្ពុជាក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ហើយបច្ចុប្បននេះមានកំរិតប្រហាក់ប្រហែលគ្នាទៅនឹងប្រទេសថៃដែរ។ ខេត្តព្រៃវែងមិនឈប់ត្រឹមនេះទេ អាជ្ញាធរមានផែនការបន្តបង្កើនការចំណាយទៅលើការអប់រំបន្តទៀត ។

ខេត្តព្រៃវែងក៏ជាតំបន់ដែលមានសាកលវិទ្យាល័យ និងគ្រឹះស្ថានសិក្សានានាឈានមុខគេផងដែរ ក្នុងចំណោមនោះ សាកលវិទ្យាល័យវេទមហាឫស្សី (MVU) បានដើរតួទាំងស្រុងក្នុងការអប់រំអ្នកដឹកនាំអាជីវកម្មថ្មីនៃប្រទេស ។

**ប្រជាសាស្ត្រអនុគ្រោះ**[5]




## ៣. វិស័យសេវាហិរញ្ញវត្ថុដ៏ខ្លាំងក្លា

ដោយសារមានការកើនឡើងនៃចំនួនប្រជាជនថ្នាក់កណ្ដាល វិស័យសេវាហិរញ្ញវត្ថុនៅក្នុងខេត្តត្រូវបានអភិវឌ្ឍន៍យ៉ាងល្អ ។ មានសាខាធនាគារចំនួន ១២ នៅក្នុងខេត្តព្រៃវែង ។

ចំណែកឯអាជីវកម្មធុនតូចរបស់យើងវិញ ស្ថាប័នមីក្រូហិរញ្ញវត្ថុ ដែលមានការិយាល័យសរុបចំនួន២៤នៅក្នុងខេត្តមានអ្នកខ្ចីចំនួនជិត៧៥,000នាក់ ។ត្រូវជា៧% នៃចំនួនប្រជាជនជាចំនួនច្រើនជាងចំនួនប្រជាជនគិតជាមធ្យម ។អាជីវកម្មរបស់យើងទទួលបាននូវ ដើមទុនដែលគេត្រូវបង្កើតវិនិយោគដែលផ្ដល់ផលខ្ពស់ ។

4. *Lonely Planet ឆ្នាំ ២00៧ ។*

5. *វិទ្យាស្ថានជាតិស្ថិតិ ជម្រឿនចំនួនប្រជាជននៅក្នុងប្រទេស កម្ពុជា ឆ្នាំ ២00៤ ។*





### ៤. អចលនទ្រព្យដែលមានតម្លៃខ្ពស់លើសលប់ លក់ក្នុងតម្លៃទាប

ខេត្តព្រៃវែងគឺជាតំបន់ដែលមានទំហំមធ្យម ដែលមានផ្ទៃដីទូលាយសំរាប់វិនិយោគិនទាំងឡាយ។ យើងគាំទ្រ និងធ្វើការយ៉ាងសកម្មជាមួយក្រុមហ៊ុននានា ដើម្បីរក្សាសុវត្ថិភាពដីសមស្របសំរាប់ក្រុមហ៊ុនធ្វើវិនិយោគទុន ។ ដីឧស្សាហកម្មអាចរកបានក្នុង តម្លៃទាបគឺ ០.៥០ដុល្លារ ក្នុង១ម៉ែត្រការ៉េ។ ដីមានជីជាតិសំរាប់វិស័យកសិកម្ម។

### ៥. សេវាទឹក និងអគ្គិសនីដែលមានលក្ខណៈប្រកួតប្រជែង

#### អគ្គិសនី

ខេត្តព្រៃវែងប្រើប្រាស់ថាមពលអគ្គិសនីចេញពីប្រភពមួយចំនួន ដែលរួមមានស្ថានីយ៍ប្រតិបត្តិការចំនួន ៤ កន្លែងក្នុងទីរួមខេត្ត និងស្ថានីយ៍អគ្គិសនីឯកជនចំនួន ១០ កន្លែងទៀតប្រតិបត្តិការនៅក្នុងស្រុកផ្សេងៗគ្នា ។ ខេត្តនេះ ក៏ទទួលបានការប្រើប្រាស់អគ្គិសនីដែលនាំចូលពីប្រទេសវៀតណាមមកផងដែរ។ រាជរដ្ឋាភិបាលបានចរចារស្តីពីការបង្កើនថាមពលអគ្គិសនីមកពីប្រទេសវៀតណាម ។ ការងារនេះបានចាប់ផ្តើមផ្គត់ផ្គង់ពីប្រទេសវៀតណាមទៅអ្នកលឿង ។ គេមានគម្រោងពង្រីកការងារនេះមកទីរួមខេត្តព្រៃវែងទៀត ។

អភិបាលខេត្តព្រៃវែងប្រឹងប្រែងយ៉ាងសកម្ម ដើម្បីស្វែងរកការវិនិយោគទុនថ្មី ដើម្បីបន្តកែលំអការផ្គត់ផ្គង់អគ្គិសនីរបស់ខេត្តឱ្យកាន់តែមានលក្ខណៈប្រសើរឡើង ហើយយល់ថាការប្រឹងប្រែងនេះជាអាទិភាពទីមួយ ឯយើងនឹងធ្វើអ្វីគ្រប់យ៉ាងដើម្បីគាំទ្រតម្រូវការរបស់អ្នកនៅក្នុងតំបន់នេះ ។

#### ទឹក

ខេត្តព្រៃវែងទទួលបានទឹកប្រើប្រាស់គ្រប់គ្រាន់ពីទន្លេធំ និងទឹកតាមដៃទន្លេតូចៗ។ មានប្រភពទឹកតាមដៃទន្លេតូចៗជាច្រើន រួមមានទន្លេមេគង្គ និងដៃរបស់វាជាដើម។ មួយភាគបីនៃខេត្តជាវាលទំនាបលិចទឹកទន្លេមេគង្គ ។ ការនាំល្បាប់មកចាក់លើតំបន់លិចទឹករាល់ឆ្នាំរឹតតែធ្វើឱ្យដីកាន់តែមានជីជាតិ ។

ទឹកក្រោមដីងាយស្រួលប្រើប្រាស់ និងមានតម្លៃថោក (មានម៉ាស៊ីនបូមទឹកប្រហែល ១១,០០០ គ្រឿងសំរាប់ប្រើប្រាស់ក្នុងខេត្ត)

## ឧស្សាហកម្មសំខាន់ៗរបស់ខេត្ត

#### កសិកម្ម

សេដ្ឋកិច្ចខេត្តព្រៃវែងពឹងផ្អែកទៅលើវិស័យកសិកម្ម ដែលមានផ្ទៃដី ២៥០ ០០០ ហិកតាជាដីធ្វើកសិកម្ម ។ ការពឹងផ្អែកធំបំផុតរបស់ខេត្តនេះគឺស្រូវ ។ ខេត្តព្រៃវែងក្នុងមួយឆ្នាំផ្តល់ទិន្នផលស្រូវបានប្រហែល ១០% នៃទិន្នផលស្រូវទាំងអស់នៅកម្ពុជា សម្រាប់ការនាំចេញទៅខេត្តផ្សេងៗទៀត ។ ខេត្តក៏មានដាំសណ្តែកបាយ អំពៅ និងល្ង បានយ៉ាងច្រើនសន្ធឹកសន្ធាប់ទៀតផង ។

នៅក្នុងខេត្តមានរោងម៉ាស៊ីនកិនស្រូវធំៗចំនួន៥៣កន្លែងរួមទាំងរោងម៉ាស៊ីនកិនស្រូវតូចៗចំនួន ២ ៦៩៨ កន្លែងទៀត ។ ការដាំដំណាំដំឡូងមីមានការកើនឡើងយ៉ាងសន្ធឹកសន្ធាប់ដែលឥឡូវនេះបានគ្របដណ្តប់លើផ្ទៃដីដែលមានទំហំ ៣ ០០០ ហិកតា (កើនឡើង ពី ១ ០០០ ហិកតា) ។

ផលិតកម្មស្រូវប្រាំង (២២% ជាតំបន់បង្កបង្កើនផលនៅក្នុងខេត្តព្រៃវែង) ត្រូវបានរំពឹងថាមានការកើនឡើង ។ រាជរដ្ឋាភិបាលកម្ពុជាមានបំណងវិនិយោគប្រាក់កំចីពីរដ្ឋាភិបាល កាតា (Qatar) ទៅក្នុងប្រព័ន្ធធារាសាស្ត្រនៅក្នុងខេត្តព្រៃវែង ដែលក្នុងគោលបំណងនេះទិន្នផលមួយផ្នែកនឹងត្រូវលក់ទៅឱ្យកាតា ។ គោលបំណងនេះ និងការកែលំអផ្សេងៗទៀតទៅលើប្រព័ន្ធបង្ហូរទឹកនៅក្នុងមូលដ្ឋាន អាចប្រមូលផលបានពីរដងក្នុងមួយឆ្នាំ ហើយទិន្នផលអាចកើនឡើងយ៉ាងខ្ពស់ ។

បន្ថែមលើនេះទៀត វិនិយោគិនមកពីប្រទេសជប៉ុន និងកូរ៉េ បាននិងកំពុងសិក្សាពីកាលានុវត្តភាពនៃការដាំដំណាំស្រូវនៅខេត្តព្រៃវែង។ ពួកគេកំពុងពិនិត្យមធ្យោបាយក្នុងការបង្កើនទិន្នផលស្រូវអោយកើនដល់ ៣តោន ក្នុងមួយឆ្នាំ ។

ដើមត្នោតជាសម្បត្តិក្នុងតំបន់ដ៏សំខាន់មួយដែលមានចំការធំៗជាច្រើន ។ ស្ករត្នោត និងផលិតផលផ្សេងទៀតបានមកពីដើមត្នោតនៅក្នុងខេត្តព្រៃវែង មានគុណភាពខ្ពស់ជាងផលិតផលត្នោតមកពីខេត្តដទៃ ។

បន្ថែមពីលើដំណាំស្រូវ និងដំណាំផ្សេងៗ យើងនៅមានការចិញ្ចឹមសត្វជាច្រើន ដែលយើងគិតថាមានប្រហែល ១០% នៃចំនួនបសុបក្សី និងជ្រូកសរុបនៅក្នុងប្រទេសកម្ពុជា ។ យើងមានត្រីទន្លេ និងវារីវប្បកម្មមួយចំនួនដែលមានស្ថានីយ៍ភ្ញាស់កូនត្រីដែលជាផ្នែកមួយនៃមន្ទីរជលផល ។

ផលិតកម្មចិញ្ចឹមសត្វ និងកសិកម្មដ៏ច្រើនសន្ធឹកសន្ធាប់របស់យើងមិនមែនជារឿងចៃដន្យទេ ។ យើងមានហេដ្ឋារចនាសម្ព័ន្ធគោលនយោបាយ និងធនធានធម្មជាតិ ដែលមានសារៈសំខាន់ចំពោះផលិតកម្មប្រកបដោយជោគជ័យនៅក្នុងវិស័យសេដ្ឋកិច្ចដ៏សំខាន់នេះ ។ អភិបាលខេត្តបានប្តេជ្ញាចិត្តក្នុងការជំរុញវិស័យកសិកម្មតាមមធ្យោបាយមួយចំនួនដូចជា:

- បង្កើនជំនាញបច្ចេកទេស
- ធ្វើអោយប្រសើឡើងនូវបច្ចេកវិជ្ជាក្រោយការប្រមូលផល
- បង្កើនគ្រាប់ពូជថ្មីៗ ដើម្បីជំរុញកំនើនទិន្នផល
- បង្កើនសមត្ថភាពកែច្នៃ
- ផ្តល់នូវពត៌មានទីផ្សារ

#### ឧស្សាហកម្ម

ដរាបណាសេដ្ឋកិច្ចសំខាន់របស់យើងនៅតែពឹងផ្អែកទៅលើវិស័យកសិកម្មទៀតនោះ ការងាររបស់យើងដែលត្រូវទាក់ទាញឧស្សាហកម្មថ្មី គឺត្រូវតែបន្តទៅទៀត។ បច្ចុប្បន្នឧស្សាហកម្មរបស់យើងរួមមានផ្នែកសិប្បកម្មដោយដៃ សហគ្រាសផលិតឥដ្ឋ និងក្បឿង និងផលិតគ្រួស និងខ្សាច់ ។ ខេត្តមានកន្លែងយកថ្មមួយចំនួន ដែលកំពុងបម្រើការដល់ផ្នែកសំណង់នៅក្នុងប្រទេសយ៉ាងខ្លាំងក្លា ក៏ដូចជានៅទីផ្សារប្រទេសវៀតណាមផងដែរ។

អាជីវកម្មថ្មីក៏ត្រូវបានស្នើសុំផងដែរ ដូចជារោងចក្រកាត់ដេរចិនថ្មីមួយដែលមានចំងាយ ១៥ គីឡូម៉ែត្រពីទីរួមខេត្តព្រៃវែង ។ វិនិយោគិនមកពីប្រទេសចិន ក៏បាននិងកំពុងសិក្សាពីការបង្កើតម៉ាស៊ីនកិនស្រូវនៅក្នុងខេត្តផងដែរ ។

យើងមានកិត្តិស័ព្ទខាងផលិតផលតម្បាញសូត្រ ហើយសូត្រដែលជាវត្ថុធាតុដើមក៏ត្រូវបានផលិតនៅក្នុងខេត្តផងដែរ ។ មានសិប្បកម្មខ្នាតតូចជាង ៤០០០ នៅក្នុងខេត្តព្រៃវែងដែលមានកម្លាំងពលកម្មជាង ៧០០០នាក់ ។





ដោយមានការគាំទ្រពីវិស័យកសិកម្មរបស់យើង និងពីប្រទេសទាំងមូល អាជីវកម្មរបស់ខេត្តយើងក៏ពាក់ព័ន្ធនឹងផលិតកម្មគ្រឿងចក្ររថយន្តដឹកកសិផល និងម៉ាស៊ីនកិនស្រូវផងដែរ ។

អាជីវកម្មធុនតូចជាច្រើនប្រតិបត្តិនៅក្នុងខេត្តរបស់យើងដែលបានចុះបញ្ជីធ្វើអាជីវកម្មជិត ៤០០ នៅសាលាខេត្តរបស់យើង ។ បន្ថែមពីលើនេះទៀត មានមីក្រូសហគ្រាសរាប់ពាន់ដែលរួមមានៈ

| សកម្មភាព | ចំនួនសហគ្រាស |
|---|---|
| ម្ហូបអាហារ ភេសជ្ជៈ ថ្នាំជក់ ការលក់រាយ | ២,៩០៥ |
| តម្បាញ ដេប៉ាក់ ថ្មម៉ូត | ១,០៩០ |
| ការកែច្នៃរ៉ែដែក | ៥៥ |
| ការកែច្នៃវត្ថុធាតុដើមមិនមែនរ៉ែដែក | ៣៩ |
| សារធាតុគីមី | ២ |
| សរុប | ៤០៩១ |

## ឱកាសអាជីវកម្ម

យើងមើលឃើញឱកាសល្អ សំរាប់អាជីវកម្មដើម្បីទាញយកកំលាំងប្រកួតប្រជែងតាមរយៈការវិនិយោគទុនបន្ថែមទៀតនៅក្នុងវិស័យៈ

- **ផលិតកម្មដំឡូងមី សណ្តែកសៀង និងពោត** ។ ដើម្បីសម្រេចបានកំណើននេះ អភិបាលខេត្តកំពុងស្វែងរកដៃគូវិនិយោគ ដើម្បីបង្កើតរោងចក្រសំរាប់ដំណាំទាំងនេះ – គំរោងបង្កើតរោងចក្រថ្មីមួយគឺត្រូវសង់ឡើងដើម្បីកែច្នៃដំឡូងមី ។ រដ្ឋាភិបាលក៏ឃើញកាលានុវត្តភាពក្នុងការវិនិយោគផ្នែកម៉ាស៊ីនកិនស្រូវ ជាពិសេសខេត្តព្រៃវែងមានដំណាំស្រូវយ៉ាងច្រើន ។

- ដោយមានចំនួន **បសុសត្វ និងសត្វជ្រូក** យ៉ាងច្រើន យើងក៏មានឱកាសជាច្រើនក្នុងការកែច្នៃសាច់សត្វផងដែរ ។ ប្រទេសកម្ពុជានាំចូលសាច់ជ្រូក ៣០០ លានតោនក្នុងមួយឆ្នាំ ។ ដោយចំនួននៃការចិញ្ចឹមជ្រូកមានយ៉ាងច្រើន ហើយខេត្តរបស់យើងមានទីតាំងជិតភ្នំពេញផង ផលអនុគ្រោះនេះផ្តល់នូវឱកាសជាច្រើនសំរាប់ការវិនិយោគទុននៅក្នុងខេត្តព្រៃវែង ។

- **ទីផ្សារផលិតផលកសិកម្ម** រួមមានបន្លែស្លឹកបៃតង ខ្ទឹ ឃ្លោក និងស្រូវសរីរាង្គ។ ស្រូវសរីរាង្គនៅខេត្តព្រៃវែង អាចលក់បានក្នុងតម្លៃ ២៥០ដុល្លារ ទៅ ៣០០ដុល្លារក្នុងមួយតោន។មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា មានគម្រោងទិញស្រូវសរីរាង្គ ២០០០ តោននៅក្នុងឆ្នាំ ២០០៨ ពី ១២០០ តោន។

- **នេសាទ និងវារីវប្បកម្ម** ។ យើងមានប្រភពទឹកធម្មជាតិដ៏ច្រើនលើសលុបក្នុងការពង្រីកឧស្សាហកម្មទាំងនេះ ។ ខេត្តព្រៃវែងក៏មានផលិតកម្មចិញ្ចឹមកូនត្រី និងទីភ្នាក់ងារស្រាវជ្រាវដែលជួយដល់ការអភិវឌ្ឍន៍វារីវប្បកម្ម ។

- **ឧស្សាហកម្មធុនស្រាល** រួមមានវិស័យកាត់ដេរជាដើម ។ កំលាំងពលកម្មយ៉ាងច្រើន និងមានតម្លៃទាប ហេដ្ឋារចនាសម្ព័ន្ធតាមបទដ្ឋានត្រឹមត្រូវ និងបរិយាកាសអាជីវកម្មអំណោយផល។ ផ្លូវជាតិថ្មី លេខ៨ នឹងអាចចូលទៅដល់ប្រទេសវៀតណាមដល់កំពង់ផែនៅទីក្រុងហូជីមិញ ដែលធ្វើដំណើរតែ៣ម៉ោងប៉ុណ្ណោះ ។

- **អនាម័យទឹក** ខេត្តព្រៃវែងកំពុងតែមានការដាក់វិនិយោគទុន ១.៣ លានដុល្លារអាមេរិកនៅក្នុងគម្រោងអនាម័យទឹកសំរាប់ទឹកស្អាត ។

## ការអភិវឌ្ឍន៍ដែលកំពុងដំណើរការ

យើងស្វែងយល់ពីតម្រូវការក្នុងការពង្រឹងហេដ្ឋារចនាសម្ព័ន្ធ ដែលជួយគាំទ្រការអភិវឌ្ឍន៍អាជីវកម្មនៅក្នុងខេត្តរបស់យើង។ យើងខិតខំពង្រឹង និងទាក់ទាញផ្នែកវិនិយោគឱ្យកាន់តែមានភាពប្រសើរឡើងថែមទៀត ។ ការអភិវឌ្ឍន៍សំខាន់ៗមួយចំនួននៅក្រោមវិធីសាស្រ្តរួមមានដូចតទៅៈ

- ដោយមានជំនួយពីធនាគារពិភពលោកនិងអង្គការ IFAD យើងបានជ្រើសរើសបណ្តុះបណ្តាល និងគាំទ្របសុពេទ្យក្នុងភូមិចំនួន ១១២០នាក់ ។ ការបណ្តុះបណ្តាលធ្វើឡើងដោយនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល ភ្នាក់ងារឯកជនទាំងនេះបានផ្តល់នូវជំនួយបច្ចេកទេសដល់កសិករដែលទទួលបានផលិតភាពចិញ្ចឹមសត្វកើនឡើង ។

- *យុទ្ធសាស្រ្តសមាហរណកម្មពាណិជ្ជកម្មវិនិច្ឆ័យរបស់រាជរដ្ឋាភិបាលកម្ពុជា។* នៅក្រោមកម្មវិធីនេះ ផលិតផលនៅក្នុងខេត្តព្រៃវែងជាច្រើនទទួលបានការគាំទ្របន្ថែមទៀត ។ ផលិតផលដែលកំណត់អត្តសញ្ញាណដោយយុទ្ធសាស្រ្តនេះ រួមមានឧស្សាហកម្មកាត់ដេរ ឧស្សាហកម្មធុនស្រាល នេសាទ ដំឡូងមី ស្រូវ សូត្រ សណ្តែកសៀង និងការដឹកជញ្ជូន ។ ជំនួយរួមមានការសម្របសម្រួលផ្នែកពាណិជ្ជកម្ម និងការផ្សព្វផ្សាយពាណិជ្ជកម្ម កំណែទម្រង់ច្បាប់ និងការកសាងសមត្ថភាពគ្រប់គ្រង និងជំនាញក្នុងតំបន់ ។

- ដៃគូអភិវឌ្ឍន៍មួយចំនួនកំពុងជួយជ្រោមជ្រែងក្នុងការអភិវឌ្ឍន៍វិស័យឯកជននៅក្នុងខេត្តព្រៃវែងក្នុងតំបន់សំខាន់ៗៈ

| គម្រោង | ដៃគូអភិវឌ្ឍន៍ | វិស័យ |
|---|---|---|
| ការធ្វើឱ្យការយល់ដឹង និងការគ្រប់គ្រងលើជម្ងឺស្រូវកាន់តែមានភាពប្រសើរឡើង | ACIAR | ដំណាំស្រូវ |
| គម្រោងពង្រីកកសិកម្មកម្ពុជា-អូស្រ្តាលី ដំណាក់កាលទី II | AusAID | កសិកម្ម |
| គម្រោងកែលំអគុណភាពកសិកម្ម | AusAID | ដំណាំស្រូវ ផ្លែឈើ និងបន្លែ |
| គម្រោងសេវាព័ត៌មានទីផ្សារ កសិកម្ម | CIDA | ផ្លែឈើ និងបន្លែ |
| កម្មវិធីអភិវឌ្ឍន៍សហគ្រាសខ្នាតតូចបំផុត ខ្នាតតូច និងខ្នាតមធ្យម (Cambodia MSME) | USAID | បសុសត្វ ត្រី ជ្រូក ការកែច្នៃផលិតផលកសិកម្ម ឡឥដ្ឋ-ក្បឿង |




## ត្រូវការស្វែងយល់បន្ថែមទៀតទេ?

សំរាប់ព័ត៌មានបន្ថែមស្ដីអំពីឱកាសវិនិយោគ និងការអភិវឌ្ឍន៍នៅក្នុងខេត្តព្រៃវែង សូមទាក់ទង:

**លោក អ៊ុំ ប៊ុនឡេង**
នាយខុទ្ទកាល័យ
ខេត្តព្រៃវែង
bunleng@camintel.com
(៨៥៥) ១២ ៣១៧ ១៥៨

**www.cambodiainvestment.gov.kh**
**www.investmentcambodia.com**
ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា - គណកម្មការវិនិយោគកម្ពុជា
ទូរស័ព្ទ: (៨៥៥) ២៣ ៩៨១ ១៥៤
www.cambodianinvestment.gov.kh

វិទ្យាស្ថានជាតិស្ថិតិ:
www.nis.gov.kh

### ក្រសួងនានា

ក្រសួងពាណិជ្ជកម្ម
www.moc.gov.kh
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ:
www.mef.gov.kh
ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល:
www.mine.gov.kh
ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ:
www.mlv.gov.kh
ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់:
www.mlmupc.gov.kh
ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍:
www.mptc.gov.kh
ក្រសួងសាធារណការណ៍ និងដឹកជញ្ជូន:
www.mpwt.gov.kh
ក្រសួងទេសចរណ៍:
www.mot.gov.kh
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ:
www.maff.gov.kh

### ផ្សេងៗ

សមាគមឧស្សាហកម្មកាត់ដេរនៅកម្ពុជា:
www.gmac-cambodia.org
វេទិកាវិស័យឯកជន-រដ្ឋាភិបាល:
www.cambodia-gpsf.org
សភាពាណិជ្ជកម្មភ្នំពេញ:
www.ppcc.org.kh
សមាគមឧស្សាហកម្មធុនតូច និងមធ្យមភ្នំពេញ
www.smecambodia.org

| ស្ថានភាពទូទៅខេត្តព្រៃវែង | |
|---|---|
| ចំនួនប្រជាជន: | 1,063,494 |
| អាយុពី 15-64: | 56.8% |
| សមាមាត្រការងារក្នុងវិស័យកសិកម្ម: | 80% |
| លំដាប់ថ្នាក់ភាពក្រីក្ររបស់ខេត្ត: | 13/24 |
| ផ្ទៃដី: | 4,883km² |
| ដង់ស៊ីតេប្រជាជន: (% ចំនួនប្រជាជនជាមធ្យម) | 275% |
| ចំនួនស្រុក: | 12 |
| ចំនួនឃុំ: | 116 |

| ស្ថានភាពដីក្នុងខេត្តព្រៃវែង | |
|---|---|
| ប្រភេទ: ដីខេត្តភាគច្រើនគឺជាដីល្បាប់ប្រផេះ ដីជាំទឹកដាំដុះ និងដីជូរ ។ ដីល្បាប់ពណ៌ត្នោតខ្ចី មាននៅជាប់មាត់ទន្លេមេគង្គ ។ | |
| កម្រិតជីវជាតិ: មធ្យម | ប្រភព: www.cambodiaatlas.com |

| អត្រាពន្ធនៅកម្ពុជា | | |
|---|---|---|
| ពន្ធលើប្រាក់ចំណេញ | ធម្មតា | 20% |
| | អត្រាប្រាក់លើកទឹកចិត្ត | 0% ឬ 9% |
| | | |
| ពន្ធអតិបរមា | | 1% ប្រាក់ចំណូល |
| ពន្ធកាត់ទុក | | 15% |
| ចំណូលបានមកពីការជួលអចលនទ្រព្យ | | 10% |
| ការទូទាត់ចំពោះមនុស្សចំណូលស្រុក | | 14% |
| ពន្ធលើប្រាក់ខែ (រៀលក្នុងមួយខែ) | | |
| 0-500,000 | | 0% |
| 500,001-1,250,000 | | 5% |
| 1,250,001-8,500,000 | | 10% |
| 8,500,001-12,500,000 | | 15% |
| 12,500,001 + | | 20% |
| មនុស្សចំណូលស្រុក | អត្រាថេរ | 20% |
| ពន្ធផលប្រយោជន៍បន្ទាប់បន្សំ | | 20% |
| តម្លៃបន្ថែមលើពន្ធ | | 10% |
| | នាំចេញ | 0% |
| ពន្ធផ្ទេរអចលនទ្រព្យ | | 4% |

| ទិន្នន័យម៉ាក្រូសេដ្ឋកិច្ចនៅកម្ពុជា | 2005 | 2006 | 2007 | 2008f | 2009f |
|---|---|---|---|---|---|
| កំណើន GDP (%) | 13.5 | 10.8 | 9.6 | 7.5 | 7.0 |
| កំណើននាំចេញ (%) | 12.6 | 19.2 | 8.1 | 5.6 | 8.5 |
| នាំចេញ (% GDP) | 64.2 | 68.0 | 66.7 | 65.7 | 66.1 |
| FDI ($m) | 375 | 475 | 598 | 660 | 759 |
| FDI (% GDP) | 6.0 | 6.5 | 6.9 | 6.7 | 6.8 |

## ចំណាយអាជីវកម្ម

| ដី | លក់ (ក្នុងមួយម៉ែត្រការ៉េ) |
|---|---|
| ភ្នំពេញ | $350-$2,000 |
| ដីសំរាប់អាជីវកម្ម | $30-$100 |
| តំបន់ផ្សេង | $4-$30 |
| ជនបទ | $0.50-$5 |
| **ដីសំរាប់ការិយាល័យ** | **តម្លៃជួលក្នុងមួយខែ** |
| សំខាន់ | $9-11/មួយម៉ែត្រការ៉េ |
| បន្ទាប់បន្សំ | $6-8/មួយម៉ែត្រការ៉េ |
| ប្រាក់ជួលរោងចក្រ | $1.50-$2.50/មួយម៉ែត្រការ៉េក្នុងមួយខែ |
| ប្រាក់ជួលឃ្លាំង | $1.00-$2.50/មួយម៉ែត្រការ៉េក្នុងមួយខែ |

| តម្លៃអគ្គិសនីនៅភ្នំពេញ (excl. SEZs) | | |
|---|---|---|
| ឧស្សាហកម្ម | គីឡូវ៉ាត់ម៉ោង/ខែ | តម្លៃ (រៀល/គីឡូវ៉ាត់) |
| | <45,000 | 600 |
| | 45,000-130,000 | 550 |
| | >130,000 | 500 |
| | កំលាំងវ៉ុលជាមធ្យម | 480 |
| ពាណិជ្ជកម្ម | <45,000 | 650 |
| | 45,000-130,000 | 600 |
| | >130,000 | 500 |
| | កំលាំងវ៉ុលជាមធ្យម | 480 |
| ការផ្គត់ផ្គង់ឧស្ម័នឧស្សាហកម្ម | | $0.32/គ.ក្រ |

| តម្លៃពលកម្ម | ប្រាក់ខែ $ ក្នុងមួយខែ |
|---|---|
| អ្នកគ្រប់គ្រងជាន់ខ្ពស់ | 1,000-1,500 |
| អ្នកគ្រប់គ្រងកណ្តាល | 500-1,000 |
| អ្នកគ្រប់គ្រងកម្រិតដំបូង | 240-400 |
| គណនេយ្យករ | 250-400 |
| លេខាធិការ | 120-150 |
| ជំនួយការ | 100-120 |
| អ្នកបើកបរ | 100-120 |
| អ្នកយាមទ្វារ | 50-80 |
| កម្មករ | 50-80 |
| ប្រាក់ឈ្នួលអប្បបរមារបស់កម្មករកាត់ដេរ | 60 |

# ខេត្តព្រៃវែង

## សក្តានុពលវិនិយោគ



Photographs by Nathan Horton www.nathanhortonphotography.com

Designed by DESIGNGROUP www.dgcambodia.com